# សេចក្តីព្រាងសុន្ទរកថា
# **ឯកឧត្តម សុខ ចិន្តាសោភា**
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤

*****

*ឯកឧត្តម លោកជំទាវ ជាភ្ញៀវកិត្តិយស*
*ឯកឧត្តម លោកជំទាវ លោក លោកស្រី*
*អង្គសន្និបាតទាំងមូលជាទីមេត្រី!*

១. ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ និងសូមស្វាគមន៍យ៉ាងកក់ក្តៅបំផុត ចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ ជាភ្ញៀវកិត្តិយស ដែលអញ្ជើញមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធនានា និងវត្តមានរបស់ថ្នាក់ដឹកនាំ អ្នកការទូត មន្ត្រីរាជការ និងបុគ្គលិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅក្នុង**ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួង** នាព្រឹកនេះ។ ឱកាសនេះជាការជួបជុំអ្នកការទូតរបស់យើងលើកដំបូង នៅក្នុងអាណត្តិថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា។

២. ខ្ញុំសូមអរគុណ **ឯកឧត្តម ស៊ា កុសល** រដ្ឋលេខាធិការប្រចាំការ ចំពោះរបាយការណ៍បូកសរុបការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួង។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះរបាយការណ៍ប្រកបដោយអត្ថន័យគ្រប់ជ្រុងជ្រោយ និងដែលបានរំលេចឱ្យឃើញពីស្នាដៃជាច្រើនដែលសម្រេចបានក្នុងឆ្នាំកន្លងទៅ ជាពិសេសក្នុងការបន្តនិរន្តរភាព នៃគោលនយោបាយការបរទេសអព្យាក្រឹតអចិន្ត្រៃយ៍ របស់កម្ពុជា ដោយឯករាជ្យ ផ្អែកលើច្បាប់ និងមានភាពបត់បែន ម៉ឺងម៉ាត់ ថ្លឹងថ្លែងប្រកបដោយភាពបុរេសកម្ម ដែលអាចឆ្លើយតបទៅនឹងការវិវត្តឥតឈប់ឈរ និងការប្រែប្រួលដ៏ជ្រាលជ្រៅនិងស្មុគស្មាញ នៃស្ថានការណ៍ទាំងក្នុងតំបន់ និងពិភពលោក។

របោយការណ៍នេះ បានឆ្លុះបញ្ចាំងការបន្តធ្វើពិពិធកម្មទំនាក់ទំនងការទូត តាម រយៈការពង្រឹងទំនាក់ទំនងជាប្រពៃណីជាមួយមិត្តចាស់ ការបង្កើនភាពជាដៃគូជាមួយមិត្តថ្មី និងការជំរុញការអនុវត្តការទូតសេដ្ឋកិច្ច និងវប្បធម៌ ព្រមទាំងសមិទ្ធផលទាំងឡាយដែលសម្រេចបានក្នុងការកែទម្រង់ស្ថាប័ន។

៣. ជាមួយគ្នានេះ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះក្រុមការងារដែលបានរៀបចំឱ្យមានវគ្គសិក្ខាសាលាស្តីពី «ការគ្រប់គ្រងវិបត្តិ» និង «កិច្ចប្រជុំបូកសរុបលទ្ធផលការងារការទូតសេដ្ឋកិច្ច» ដើម្បីជួយបង្កើនសមត្ថភាពអ្នកការទូតនិងមន្ត្រីរាជការយើង ក្នុងការគ្រប់គ្រង និងការដោះស្រាយវិបត្តិបន្ទាន់ជាយថាហេតុ ព្រមទាំងជួយពង្រឹងដល់ការអនុវត្តការងារការទូតសេដ្ឋកិច្ច និងវប្បធម៌។

៤. ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរចំពោះការឆ្លើយតបបានទាន់ពេលវេលា និងមានប្រសិទ្ធភាពរបស់អ្នកការទូត និងមន្ត្រីរាជការ របស់យើង ដែលមានមនសិការស្នេហាជាតិយ៉ាងស្មោះស្ម័គ្រ ខិតខំបំពេញការងារជូនជាតិមាតុភូមិ ហើយតែងតែយកចិត្តទុកដាក់តម្កល់ផលប្រយោជន៍ជាតិជាធំ ការពារអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី ការធានាដល់សុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ដោយមិនខ្លាចភាពនឿយហត់ ទោះបីចំនួនអ្នកការទូត មន្ត្រីរាជការ និងបុគ្គលិកយើងទាំងនៅក្នុង និងក្រៅប្រទេស មានចំនួនកំណត់ក៏ដោយ។

៥. យ៉ាងណាមិញ យើងនៅមានការងារជាច្រើនទៀតដែលត្រូវធ្វើចំពោះមុខ និងនៅឆ្នាំខាងមុខជាបន្តបន្ទាប់។ ស្ថានការណ៍ក្នុងតំបន់ និងអន្តរជាតិ មានជាអាទិ៍ វិបត្តិនៅមីយ៉ាន់ម៉ា បញ្ហាសមុទ្រចិនខាងត្បូង ស្ថានភាពឧបទ្វីបកូរ៉េ សង្គ្រាមនៅអ៊ុយក្រែន បញ្ហានៅមជ្ឈិមបូព៌ា (ជម្លោះអ៊ីស្រាអែល និងក្រុមហាម៉ាស់) ភាពតានតឹងនៃការប្រកួតប្រជែង ភូមិសាស្ត្រនយោបាយ រួមទាំងបញ្ហាសន្តិសុខប្រពៃណី និងសន្តិសុខមិនប្រពៃណីដទៃទៀត ដូចជាការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយធម្មជាតិ សន្តិសុខ ស្បៀងនិងថាមពលជាដើមកំពុងនៅជាបញ្ហាបន្ទាន់ដែលត្រូវដោះស្រាយរួមគ្នា។ ទន្ទឹមគ្នានេះ ស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកលនៅមានភាពផុយស្រួយនៅឡើយ ទោះបីត្រូវបានស្តារឡើងវិញជាបណ្តើរៗក្តី។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូល!*

៦. ស្ថិតក្នុងបរិបទខាងលើ និងក្នុងគោលដៅបន្តអនុវត្តឱ្យបានជោគជ័យនូវនយោបាយការបរទេស និងការងារការទូតបុរេសកម្ម ឯករាជ្យ ផ្អែកលើច្បាប់ យើងត្រូវខិតខំតាមដាន វិភាគ និងវាយតម្លៃសភាពការណ៍តំបន់ និងពិភពលោក ព្រមទាំងពង្រឹងសមត្ថភាពស្ថាប័ន សំដៅប្រែក្លាយបញ្ហាប្រឈមនានាទៅជាកាលានុវត្តភាព និងបង្កើនផលប្រយោជន៍ស្នូលជាអតិបរមា សម្រាប់ជាតិ។

៧. ដូច្នេះ ការងារចាំបាច់ដែលយើងនឹងបន្តធ្វើនោះ គឺ ការបន្តកសាងសមត្ថភាព វិជ្ជាជីវៈ និងបណ្តុះបណ្តាលធនធានមនុស្ស ជាពិសេសក្នុងកិច្ចការការទូត ការងារការបរទេស និងទំនាក់ទំនងអន្តរជាតិ ដើម្បីឱ្យមន្ត្រីការទូតរបស់យើងកាន់តែមានភក្តីភាពចំពោះជាតិ ប្រកបដោយវិជ្ជាជីវៈ និងទទួលបានជំនាញថ្មីៗគ្រប់គ្រាន់ មានភាពប៉ិនប្រសប់ មានសមត្ថភាពខ្ពស់ វាងវៃ បត់បែន និងក្លាយជាយុទ្ធជនឈានមុខ ក្នុងការការពារផលប្រយោជន៍ជាតិ និងប្រជាជន។

៨. ការងារខាងលើនេះ ត្រូវបន្តធ្វើជាប្រចាំ ពុំឈប់ឈរ បើពុំដូច្នោះទេ យើងមិនអាចឆ្លើយតបបានទៅនឹងតម្រូវការការងារផ្ទៃក្នុង ការវិវត្តឥតឈប់ឈរនៃបញ្ហាតំបន់ និងសភាពការណ៍ពិភពលោក។ កិច្ចការទាំងនេះ គឺជាការអនុវត្តយ៉ាងត្រឹមត្រូវស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលបន្តកំណត់យក "មនុស្ស" ជាអាទិភាពទី១ ក្នុងចំណោមអាទិភាពគន្លឹះទាំង៥ ដើម្បី "ជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារ ធានាសមធម៌ បង្កើនប្រសិទ្ធភាព និងរក្សាចីរភាព"។

៩. ការអញ្ជើញបំពេញទស្សនកិច្ច និងការចូលរួមកិច្ចប្រជុំនៅបរទេសជាច្រើនរបស់ **សម្តេចធិបតី** ក្រោយពីការចាប់បដិសន្ធិរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ ភ្លាម គឺជាគំរូវីរភាពដ៏ល្អឥតខ្ចោះនៃ «**ការងារការទូតដ៏សកម្មក្លៀវក្លាមិនខ្លាចនឿយហត់ដើម្បីស្វែងរកឧត្តមប្រយោជន៍ជូនជាតិមាតុភូមិ និងប្រជាជន**» ជាទីស្រលាញ់ដ៏ជ្រាលជ្រៅបំផុត នៃយើងទាំងអស់គ្នា។ កិច្ចការទាំងអស់នេះមិនត្រឹមតែលើកកម្ពស់កិត្យានុភាពជាតិឱ្យខ្ពស់ត្រដែតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានជួយជំរុញសម្ទុះនៃ

កំណើនសេដ្ឋកិច្ច តាមរយៈការកៀរគរការវិនិយោគបរទេស ជំនួយបច្ចេកទេស និង ប្រភពហិរញ្ញវត្ថុមកដល់កម្ពុជា ផងដែរ។

១០. ដើម្បីជំរុញ និងលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ក្រសួងយើងបន្ថែមទៀត ខ្ញុំនឹង ដឹកនាំកិច្ចប្រជុំចង្អៀត ក្នុងរយៈពេល ១ថ្ងៃកន្លះនេះ ដោយពិភាក្សាក្រោមមូលបទ **ការងារកំណែទម្រង់របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ៖ «បង្កើនប្រសិទ្ធភាព ផលិតភាព និងគុណភាពការងារ»** ជាមួយនឹងការផ្តោតលើ ការងារបន្តកំណែទម្រង់ផ្ទៃក្នុងក្រសួង និងការងារកំណែទម្រង់ស្ថានតំណាងកម្ពុជានៅ បរទេស ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** ដែលបានលើកឡើងថា "**ចាប់ផ្តើមពីការពង្រឹងរៀបចំផ្ទះរបស់យើងឱ្យបានរឹងមាំជាមុន សិន**"។

១១. ក្នុងន័យនេះ ខ្ញុំបានសម្រេចដាក់ចេញនូវប្រធានបទសំខាន់ៗ សម្រាប់យើងធ្វើការ ពិភាក្សា ក្នុងការដ្ឋានសម្អាតផ្ទះយើង លើការដ្ឋានកំណែទម្រង់របស់ក្រសួងយើង រួមមាន៖ ការងារកំណែទម្រង់ហិរញ្ញវត្ថុ, ការងារកំណែទម្រង់ការងាររដ្ឋបាល, របៀបរបប ការងារនិងរំហូរឯកសារ, ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(IT)ផ្ទៃក្នុង, បញ្ហា ធនធានមនុស្ស, និងប្រព័ន្ធលើកទឹកចិត្តមន្ត្រី, ព្រមទាំងការពង្រឹងតួនាទី និងគុណភាព សកម្មភាព នៃការងារការទូតរបស់ស្ថានតំណាងកម្ពុជាយើង នៅបរទេស។

១២. ឆ្លើយតបទៅនឹងប្រធានបទខាងលើនេះ ខ្ញុំសង្ឃឹមជឿជាក់ និងសូមលើកទឹកចិត្តដល់ ថ្នាក់ដឹកនាំ និងមន្ត្រីការទូតយើងទាំងអស់ ចូលរួមជជែកវែកញែក ពិភាក្សាផ្លាស់ប្តូរ ទស្សនៈគ្នា ដោយត្រង់ទៅត្រង់មក ដើម្បីដោះស្រាយរួមគ្នាលើបញ្ហានីមួយៗ និង ឈានដល់ការដាក់ចេញនូវយុទ្ធសាស្ត្រ គំនិតផ្តួចផ្តើម ឬគោលជំហរសំខាន់ ក៏ដូចជា ការរៀបចំផែនការនិងវិធានការងារជាក់ស្តែង ច្បាស់លាស់ ចំគោលដៅ គ្រប់ជ្រុងជ្រោយ និងប្រកបដោយប្រសិទ្ធភាពនិងផលិតភាពខ្ពស់ សំដៅសម្រេចឱ្យបាននូវបេសកកម្ម ការទូតដ៏ឧត្តុង្គឧត្តមរបស់យើង ជូនដល់ជាតិមាតុភូមិ និងប្រជាជនយើង ជាពិសេស ក្នុងការបន្តអនុវត្តសកម្មភាពការងារធំៗ ទាំងប្រាំ គឺ៖

- <u>ការងារទី១</u>៖ ការការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី

- <u>ការងារទី២៖</u> ការអនុវត្តគោលនយោបាយការបរទេសប្រកបដោយភាពបត់បែន វាងវៃ ឆ្លើយតបទៅនឹងសម្ពាធភូមិសាស្ត្រនយោបាយ
- <u>ការងារទី៣៖</u> ការអនុវត្តការងារការទូតសេដ្ឋកិច្ច និងវប្បធម៌
- <u>ការងារទី៤៖</u> ការចូលរួមក្នុងបុព្វហេតុសន្តិភាព ស្ថិរភាព និងដំណោះស្រាយបញ្ហាប្រឈមនានា នៅក្នុងពិភពលោក និង
- <u>ការងារទី៥៖</u> ការកែទម្រង់ផ្ទៃក្នុងក្រសួង ដើម្បីរៀបចំអង្គអ្នកការទូត ប្រកបដោយវិជ្ជាជីវៈ ស្នេហាជាតិ សកម្ម និងមានសមត្ថភាព។

១៣. នាពិធីបិទអង្គសន្និបាត នៅរសៀលថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ យើងនឹងបូកសរុបលទ្ធផលសំខាន់ៗនៃកិច្ចពិភាក្សារបស់យើង ដើម្បីគោរពរាយការណ៍ជូន **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងគោរពស្នើសុំអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់បំផុត និងចក្ខុវិស័យប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចធិបតី** សម្រាប់ជាត្រីវិស័យ ក្នុងការបំពេញការងារការទូតរបស់យើង សំដៅសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត ក្នុងឆ្នាំ២០២៤នេះ ក៏ដូចជាបន្តទៅឆ្នាំខាងមុខៗទៀត។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូល!*

១៤. ខ្ញុំជឿជាក់ថា សន្និបាតរបស់យើងនឹងប្រព្រឹត្តទៅដោយសកម្ម ឈរលើផលប្រយោជន៍ជាតិជាធំ និងទទួលបានជោគជ័យផ្លែផ្កាត្រចះត្រចង់។

១៥. ជាទីបញ្ចប់នេះ ខ្ញុំសូមអរគុណថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ជាន់ថ្នាក់ ទាំងនៅក្រសួង និងក្រៅប្រទេស ចំពោះការខិតខំចូលរួមបំពេញការងារយ៉ាងសកម្ម និងជាប្រចាំក្នុងការងាររបស់ក្រសួង និងសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី នូវពុទ្ធពរទាំងបួនប្រការកុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបើកជាផ្លូវការ «**សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**» ចាប់ពីពេលនេះតទៅ៕

*សូមអរគុណ !*